រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: 7

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងមហាផ្ទៃ ស្តីពីការអនុវត្តច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក

នាពេលថ្មីៗកន្លងមកនេះ មានមជ្ឈដ្ឋានកាសែតក្នុងស្រុកមួយចំនួនបានធ្វើបទសម្ភាសពាក់ព័ន្ធនឹងការអនុវត្តច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលត្រូវបានប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/ ០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ដោយចាត់ទុក និងយល់ឃើញថា មាត្រាមួយចំនួននៃច្បាប់នេះបានរំលោភលើមាត្រាជាច្រើននៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងនោះក៏បានបញ្ជាក់ថា ច្បាប់នេះងាយស្រួលឲ្យរាជរដ្ឋាភិបាលធ្វើការរំលោភអំណាច តាមរយៈការប្រើប្រាស់មាត្រានានាដើម្បីគំរាមកំហែង និងដាក់ទណ្ឌកម្មដល់សកម្មជនសិទ្ធិមនុស្សដើម្បីលិទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងសិទ្ធមនុស្សក្នុងប្រទេសកម្ពុជា។

ពាក់ព័ន្ធនឹងការលើកឡើងខាងលើនេះ ក្រសួងមហាផ្ទៃសូមធ្វើការបដិសេធនូវរាល់ការលើកឡើងគ្មានមូលដ្ឋានផ្អែកច្បាប់ត្រឹមត្រូវ និងមិនសមហេតុផល ក្នុងចេតនាមួលបង្កាច់មកលើរាជរដ្ឋាភិបាលកម្ពុជា។ ទន្ទឹមនេះ ក្រសួងមហាផ្ទៃមានកិត្តិយសសូមជម្រាបជូនដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ក៏ដូចជាសាធារណៈមតិជាតិ-អន្តរជាតិ មេត្តាជ្រាបថា៖

១. ក្រសួងមហាផ្ទៃសូមគូសបញ្ជាក់ឡើងវិញថា រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានចាត់ទុកសមាគម អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលគឺជាដៃគូមួយដ៏មានសារៈសំខាន់ និងមិនអាចខ្វះបានក្នុងការចូលរួមចំណែកកសាងប្រទេសជាតិ និងបានលើកទឹកចិត្តតាមគ្រប់រូបភាពដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលនានា ដែលកំពុងធ្វើសកម្មភាពបម្រើប្រជាពលរដ្ឋនៅទូទាំងប្រទេស ក្នុងកិច្ចដំណើរការស្តារ និងអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងការគាំពារលើកស្ទួយការអនុវត្តលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ស្របតាមច្បាប់ និងគោលការណ៍ដែលបានកំណត់។

២. ផ្អែកលើក្របខ័ណ្ឌនៃការលើកកម្ពស់នីតិរដ្ឋ និងប្រសិទ្ធភាពនៃកិច្ចសហការរវាងរាជរដ្ឋាភិបាល និងសង្គមស៊ីវិល ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានតាក់តែងឡើងដោយផ្អែកលើមូលដ្ឋានរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា៤២ កថាខ័ណ្ឌទី១ ដែលបានចែងថា "ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគម និងគណបក្សនយោបាយ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់" ច្បាប់នានាជាធរមាននៅកម្ពុជា និងលើមូលដ្ឋានមាត្រា២០ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា២២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិប្រជាពលរដ្ឋ និងសិទ្ធិនយោបាយ ព្រមទាំងមាត្រា១៥ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ។ ទន្ទឹមនេះដែរ ក្នុងដំណើរការតាក់តែងច្បាប់នេះ ក៏បានធ្វើការពិគ្រោះយោបល់

យ៉ាងទូលំទូលាយជាមួយសមាគម អង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធជាច្រើនដំណាក់កាល ចាប់តាំងពីពាក់កណ្ដាលឆ្នាំ១៩៩៥ មក ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ។

៣. រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាក្រសួងមហាផ្ទៃ មិនមានគោលបំណង និងគោលដៅណាមួយរឹតត្បិតសិទ្ធិសេរីភាពក្នុងការបង្កើត និងការធ្វើសកម្មភាពរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល រួមទាំងសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិក្នុងសង្គមប្រជាធិបតេយ្យ ដែលសិទ្ធសេរីភាព និងនីតិរដ្ឋ គឺជាកិច្ចដំណើរការដែលមិនអាចកាត់ផ្ដាច់ពីគ្នាបានឡើយ។ មាត្រា៤១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានចែងថា " ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះ ដោយរំលោភនាំឲ្យប៉ះពាល់ដល់កិត្តិយសអ្នកដទៃ ដល់ទំនៀមទំលាប់ល្អរបស់សង្គម ដល់សណ្ដាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិឡើយ "។

៤. ក្រសួងមហាផ្ទៃ សូមបញ្ជាក់ថាផ្អែកតាមគោលបំណង គោលដៅ និងខ្លឹមសារសំខាន់ៗនៃច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល បានផ្ដល់អត្ថប្រយោជន៍ដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលក្នុងនោះរួមមានជាអាទិ៍៖

- សមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលតម្កល់ឯកសារសុំចុះបញ្ជីនៅក្រសួងមហាផ្ទៃ ត្រូវបានចាត់ទុកជាការចុះបញ្ជីដោយស្របច្បាប់ និងទទួលបានជាស្វ័យប្រវត្តិនូវឋានៈជានីតិបុគ្គលដែលច្បាប់ការពារមិនឲ្យមានការរំលោភបំពានណាមួយឡើយ។ ចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលបានចុះអនុស្សរណៈជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវចាត់ទុកថាបានចុះបញ្ជី និងអាចធ្វើសកម្មភាពរហូតដល់ថ្ងៃផុតកំណត់សុពលភាពអនុស្សរណៈ។

- បង្កលក្ខណៈសម្បត្តិងាយស្រួលដល់ការកកើតឡើងនូវសមាគម និងអង្គការមិនមែនរដ្ឋាភិបាលថ្មីៗបន្ថែមទៀត ដើម្បីបន្តចូលរួមចំណែកអភិវឌ្ឍសង្គមកម្ពុជាលើគ្រប់វិស័យ ដែលក្នុងនោះបែបបទ និងនីតិវិធីនៃការបង្កើត និងការចុះបញ្ជីមានលក្ខណៈសាមញ្ញ មិនស្មុគស្មាញ និងការិយាធិបតេយ្យដូចនៅបណ្ដាប្រទេសមួយចំនួននៅក្នុងតំបន់នោះឡើយ។ បន្ទាប់ពីច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចូលជាធរមានកាលពីថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ កន្លងមក រហូតមកដល់ត្រឹមដំណាច់ខែឧសភា ឆ្នាំ២០១៦ មានសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចំនួន១៧៧ បានបង្កើត និងចុះបញ្ជីស្របតាមច្បាប់នេះ ក្នុងនោះមានសមាគមចំនួន១០២ និងអង្គការមិនមែនរដ្ឋាភិបាលចំនួន៧៥។

- ច្បាប់បានដាក់កាតព្វកិច្ចដល់ស្ថាប័នសាធារណៈទាំងអស់ ត្រូវតែលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីចូលរួមអភិវឌ្ឍប្រទេសជាតិលើគ្រប់វិស័យ។

- សមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ ទទួលបានការលើកទឹកចិត្ត និងការអនុគ្រោះនានាស្របតាមច្បាប់ និងបទប្បញ្ញត្តិនានាជាធរមាន។

- សមាគម និងអង្គការមិនមែនរដ្ឋាភិបាល មានសិទ្ធគ្រប់គ្រាន់ក្នុងការធ្វើសកម្មភាពស្របច្បាប់ និងស្របតាមលក្ខន្តិកៈរបស់ខ្លួន ដោយគ្មានស្ថាប័ន អង្គការ ឬបុគ្គលណាមួយមករំលោភបំពានបានឡើយ។

ក្នុងគោលបំណងនាំសង្គមកម្ពុជាទៅរកការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ និងកិច្ចសហប្រតិបត្តិការល្អក្នុងភាពជាដៃគូអភិវឌ្ឍន៍ ក្រសួងមហាផ្ទៃ សូមស្នើដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលបានតម្កល់សំណុំឯកសារសុំចុះបញ្ជីនៅក្រសួងមហាផ្ទៃ ត្រូវធ្វើសកម្មភាពឲ្យស្របតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងអនុវត្តឲ្យបានត្រឹមត្រូវទៅតាមលក្ខន្តិកៈរបស់ខ្លួន ដោយមិនមានការរើសអើង ការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ឬសាសនាណាមួយឡើយ ព្រមទាំងត្រូវប្រកាន់នូវជំហរអព្យាក្រឹត្យ ចំពោះគ្រប់គណបក្សនយោបាយដែលធ្វើសកម្មភាពស្របច្បាប់នៅកម្ពុជា ដើម្បីបំពេញបេសកកម្មរបស់ខ្លួន ប្រកបដោយគណនេយ្យភាព មានប្រសិទ្ធភាព និងតម្លាភាព ជាពិសេសក្នុងស្មារតីឆ្លើយតបទៅនឹងការវិវត្ត នៃសភាពការណ៍សង្គមនាពេលបច្ចុប្បន្ន ក្នុងគោលបំណងពង្រឹងនីតិរដ្ឋនៅកម្ពុជាឲ្យកាន់តែរឹងមាំ ស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស។

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៦